# ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច ផ្នែកទី ៣



ស្គាល់សេចក្តីពិតដែលទាក់ទងទៅនឹងការផ្លាស់ប្រែចិត្តជឿរបស់ក្មួយៗ ។ សេចក្តីពិតនោះគឺថា ក្មួយៗត្រូវតែទទួលខុសត្រូវលើការផ្លាស់ប្រែចិត្តជឿផ្ទាល់ខ្លួនរបស់ក្មួយ ។ គ្មាននរណាផ្សេងទៀតអាចធ្វើវាជំនួសក្មួយៗបានទេ ។

ឥឡូវ តើខ្ញុំអាចសុំឲ្យក្មួយៗពិចារណាអំពីសំណួរមួយចំនួនបានឬទេ ? តើក្មួយៗចង់ទទួលភាពសុខសាន្តពីកង្វល់ ដែលញាំញីក្មួយៗនៅពេលបច្ចុប្បន្ននេះដែរឬទេ ? តើក្មួយៗចង់ស្គាល់ព្រះយេស៊ូវគ្រីស្ទឲ្យកាន់តែច្បាស់ដែរឬទេ ? តើក្មួយៗចង់រៀនអំពីរបៀបដែលព្រះចេស្ដាដ៏ទេវភាពរបស់ទ្រង់អាចព្យាបាលរបួស និងភាពទន់ខ្សោយរបស់ក្មួយៗដែរឬទេ ? តើក្មួយៗចង់ដកពិសោធន៍នូវព្រះចេស្ដាដ៏ទន់ភ្លន់ផ្អែមល្ហែមនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលដំណើរការនៅក្នុងជីវិតរបស់ក្មួយៗដែរឬទេ ?

ការស្វែងរកចម្លើយចំពោះសំណួរទាំងនេះនឹងតម្រូវឲ្យមានការខិតខំ—គឺការខិតខំយ៉ាងខ្លាំង ។ ខ្ញុំសូមអង្វរក្មួយៗឲ្យចេះទទួលខុសត្រូវនៅលើទីបន្ទាល់របស់ក្មួយៗ ។ សូមខិតខំដើម្បីមានទីបន្ទាល់នោះ ។ សូមមានវាផ្ទាល់ខ្លួន ។ សូមថែទាំវា ។ សូមចិញ្ចឹមបីបាច់វា ដើម្បីឲ្យវាលូតលាស់ ។ សូមពង្រឹងវាដោយសេចក្តីពិត ។ សូមកុំបំពុលទីបន្ទាល់ដោយទស្សនវិជ្ជាខុសឆ្គងរបស់បុរស និងស្ត្រីដែលមិនជឿ ហើយក្រោយមកងឿងឆ្ងល់ថាហេតុអ្វីបានជាទីបន្ទាល់របស់ក្មួយៗមានភាពសោះកក្រោះនោះឡើយ ។

សូមធ្វើការអធិស្ឋានដ៏រាបសាដោយស្មោះប្រចាំថ្ងៃ ។ សូមចិញ្ចឹមបីបាច់ខ្លួនក្មួយៗដោយប្រសាសន៍របស់ព្យាការីសម័យបុរាណ និងសម័យថ្មី ។ ទូលសូមព្រះអម្ចាស់ឲ្យបង្រៀនក្មួយអំពីរបៀបស្តាប់ឮទ្រង់ឲ្យកាន់តែល្អប្រសើរ ។ សូមចំណាយពេលឲ្យច្រើននៅក្នុងព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ ។

ពេលក្មួយៗដាក់ទីបន្ទាល់ជាអាទិភាពដ៏ខ្ពស់បំផុតរបស់ក្មួយ សូមចាំមើលពីអព្ភូតហេតុកើតឡើងនៅក្នុងជីវិតរបស់ក្មួយៗ ។

បើក្មួយៗមានសំណួរ—ខ្ញុំសង្ឃឹមថាក្មួយៗនឹងមាន—សូមស្វែងរកចម្លើយដោយមានបំណងប្រាថ្នាដ៏ក្លៀវក្លាដើម្បីជឿ ។ សូមរៀនអំពីដំណឹងល្អតាមដែលក្មួយអាចរៀនបាន ហើយត្រូវប្រាកដថា បានងាកទៅរកប្រភពដែលពោរពេញដោយសេចក្តីពិត ដើម្បីសូមការណែនាំ ។ យើងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាដែល « គ្មានអ្វីណាមួយដែលត្រូវរក្សាទុកនោះឡើយ » ។ [ គោលលទ្ធិ និងសេចក្តីសញ្ញា ១២១:២៨ ] ។ ដូច្នេះហើយ លុះពេលវេលាមកដល់ នោះព្រះអម្ចាស់នឹងឆ្លើយរាល់សំណួររបស់យើង ។

ប៉ុន្តែឥឡូវនេះ សូមពន្លិចខ្លួនក្មួយៗទៅក្នុងអាងនៃវិវរណៈដ៏បរិបូរណ៍ ដែលយើងមាននៅចុងម្រាមដៃរបស់យើង ។ ខ្ញុំសូមសន្យាថា ការធ្វើបែបនេះនឹងពង្រឹងដល់ទីបន្ទាល់របស់ក្មួយៗ ទោះជាសំណួរមួយចំនួនរបស់ក្មួយពុំទាន់មានចម្លើយក្តី ។ សំណួរដ៏ស្មោះរបស់ក្មួយ ដែលបានសួរដោយសេចក្តីជំនឿនឹងដឹកនាំទៅរកសេចក្តីជំនឿកាន់តែធំ និងចំណេះដឹងកាន់តែច្រើន *ជានិច្ច* ។ . . .

ពេលក្មួយៗទទួលខុសត្រូវលើទីបន្ទាល់របស់ខ្លួន ហើយធ្វើឲ្យវាលូតលាស់ នោះក្មួយៗនឹងក្លាយជាឧបករណ៍កាន់តែមានតម្លៃនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។ ក្មួយៗនឹងត្រូវបាន « លើកទឹកចិត្ត ដោយហេតុមួយដ៏ប្រសើរ » [ អាលម៉ា ៤៣:៤៥ ]—គឺបុព្វហេតុរបស់ព្រះយេស៊ូវគ្រីស្ទ !

*ចំពោះទ្រង់* គ្មានអ្វីកើតឡើងនៅលើផែនដីនេះសំខាន់ជាងការប្រមូលផ្តុំនៃអ៊ីស្រាអែលឡើយ ។ ចូរអនុញ្ញាតឲ្យព្រះវរបិតាសួគ៌របស់ក្មួយៗដឹងថា ក្មួយៗចង់ជួយ ។ ចូរសូមឲ្យទ្រង់ដាក់ក្មួយៗឲ្យទៅធ្វើការនៅក្នុងបុព្វហេតុដ៏រុងរឿងនេះ ។ រួចហើយក្រឡេកមើលអ្វីដែលបានកើតឡើង ពេលក្មួយៗទុកឲ្យព្រះឈ្នះនៅក្នុងជីវិតរបស់ក្មួយៗ ។

មិត្តវ័យក្មេងជាទីស្រឡាញ់អើយ ខ្ញុំស្រឡាញ់ក្មួយៗ ។ ខ្ញុំសូមអរគុណ ! ខ្ញុំជឿជាក់លើក្មួយៗ ។ ក្នុងនាមជាព្យាការីរបស់ព្រះអម្ចាស់ ខ្ញុំសូមប្រទានពរឲ្យក្មួយអាចស្គាល់សេចក្តីពិតថា ក្មួយៗជានរណា និងសូមប្រទានពរឲ្យក្មួយរក្សាសេចក្តីពិតអំពីសក្តានុពលដ៏រុងរឿងរបស់ក្មួយដ៏ពិតនោះទុក ។ ខ្ញុំសូមផ្តល់ពរឲ្យក្មួយៗទទួលខុសត្រូវលើទីបន្ទាល់របស់ខ្លួនផ្ទាល់ ។ ហើយខ្ញុំផ្តល់ពរឲ្យក្មួយៗមានបំណងប្រាថ្នា និងកម្លាំងដើម្បីរក្សាសេចក្តីសញ្ញារបស់ខ្លួន ។

ពេលក្មួយៗធ្វើដូច្នេះ ខ្ញុំសូមសន្យាថា ក្មួយៗនឹងដកពិសោធន៍នូវការរីកចម្រើនខាងវិញ្ញាណ ឈប់ភ័យខ្លាច ហើយមានទំនុកចិត្តដែលក្មួយនឹកស្មានមិនដល់នៅពេលនេះ ។ ក្មួយៗនឹងមានកម្លាំងដើម្បីមានឥទ្ធិពលវិជ្ជមានលើសពីសមត្ថភាពធម្មជាតិរបស់ក្មួយទៅទៀត ។ ហើយខ្ញុំសូមសន្យាថា អនាគតរបស់ក្មួយនឹងរីករាយជាងអ្វីដែលក្មួយអាចជឿជាក់បាន នៅពេលនេះទៅទៀត ។ ( រ័សុល អិម ណិលសុន « ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់ យុវមជ្ឈិមវ័យ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ] នៅលើគេហទំព័រ broadcasts.ChurchofJesusChrist.org )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_544_handout-3